វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១១ លេខ ០៥

## អាទិភាពគោលនយោបាយសម្រាប់កំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា[១]

### ១. ពិពិធកម្មក្នុងចំនួនវិស័យជម្រុញកំណើន និង ក្នុងមុខវិស័យនីមួយៗ

- ធ្វើពិពិធកម្មសេដ្ឋកិច្ចចេញពីការពឹងផ្អែកលើ មុខផលិតផលមួយចំនួនតូចសម្រាប់នាំចេញ។
- សម្រាប់វិស័យកសិកម្ម ត្រូវផ្តោតលើការបង្កើនផលិតភាពនៃកសិដ្ឋានតូចៗ និងការធ្វើពិពិធកម្មផលិតកម្មដោយដាក់បញ្ចូលនូវផលិតផលមានការកែច្នៃ និងមានតម្លៃខ្ពស់ ដូចជា អង្ករ ជាដើម។
- សម្រាប់វិស័យឧស្សាហកម្ម ត្រូវធ្វើពិពិធកម្មចេញពីផ្នែកកាត់ដេរ និងឈានឡើងថែមទៀតក្នុងខ្សែចង្វាក់បង្កើតតម្លៃបន្ថែម ហើយនៅក្នុងផ្នែកកាត់ដេរ ត្រូវឈានទៅផលិតសម្លៀកបំពាក់មានគុណភាពខ្ពស់ និងតម្លៃខ្ពស់។
- ធ្វើពិពិធកម្មវិស័យទេសចរណ៍ ដោយដាក់បញ្ចូលនូវអេកូទេសចរណ៍ និងទេសចរណ៍តំបន់ឆ្នេរ ព្រមទាំងបន្តបង្កើនផលចំណេញបានពីទេសចរណ៍វប្បធម៌។

### ២. កែលម្អក្របខ័ណ្ឌនានា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ

- គ្រប់គ្រងទីផ្សារឥណទានដែលរីកចម្រើនយ៉ាងលឿន ដើម្បីធានាស្ថិរភាព និងនិរន្តរភាពនៃវិស័យហិរញ្ញវត្ថុ។
- ធានាឲ្យមានសេវាឥណទាន ផ្តល់ទៅដល់ផ្នែកដែលជួយរួមចំណែកបានខ្លាំងបំផុតដល់កំណើន និងការកាត់បន្ថយភាពក្រីក្រ (ឧ. សហគ្រាសធុនតូច និងមធ្យម និងការធ្វើស្រែទ្រង់ទ្រាយតូច)។
- បង្កើតក្របខ័ណ្ឌ ដើម្បីជម្រុញវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ពីសំណាក់វិស័យឯកជន៖ គម្រោងស្តារផ្លូវដែកឡើងវិញ ជាគំរូដ៏មានប្រយោជន៍មួយសម្រាប់អនុវត្តតាម។

### ៣. រក្សាស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឲ្យមានស្ថិរភាពទៅអនាគត

- បង្កើតឱកាសខាងហិរញ្ញវត្ថុបន្ថែមទៀត ដើម្បីបង្កើនចំណាយសាធារណៈ ជាពិសេសក្នុងផ្នែកសុខាភិបាល និងអប់រំ។ ការងារសំខាន់ គឺត្រូវបង្កើនអត្រាប្រមូលប្រាក់ចំណូល។
- រក្សាឲ្យកំណើនមានតុល្យភាពល្អទៅអនាគត តាមរយៈការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសមស្រប ដើម្បីធានាឲ្យកំណើននៃវិស័យកំពុងផុសឡើងនានា មិនប៉ះពាល់ធ្វើឲ្យខូចខាតដល់វិស័យឯទៀតដែលមានស្រាប់។
- រក្សាអតិផរណាឲ្យស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន នៅចំពោះមុខកំណើនសម្ពាធផ្សេងៗ (កំណើនសេដ្ឋកិច្ច កំណើននៃចំណាយសាធារណៈ វិនិយោគ ថ្លៃផលិតផល និងការផ្តល់ឥណទាន)។

### ៤. ពង្រឹងក្របខ័ណ្ឌគោលនយោបាយសម្រាប់ពិពិធកម្មពាណិជ្ជកម្ម និងវិនិយោគ

- កសាងសមត្ថភាពស្រាវជ្រាវ ដើម្បីកំណត់នូវអន្តរាគមន៍ជាគោលនយោបាយសមស្របនានា និងវាយតម្លៃលើលទ្ធផលនៃគោលនយោបាយ ដោយផ្តោតលើឥទ្ធិពលជួយកាត់បន្ថយភាពក្រីក្រ។ តភ្ជាប់ឲ្យបានកាន់តែប្រសើរនូវលទ្ធផលនៃការស្រាវជ្រាវ ជាមួយនឹងគោលនយោបាយ។
- តម្រឹមគោលនយោបាយរបស់រដ្ឋាភិបាល និងចក្ខុវិស័យរបស់វិស័យឯកជនតាមរយៈ៖
  - ការបង្កើនសមត្ថភាពធ្វើការសន្ទនា ដើម្បីឲ្យគោលនយោបាយនានា អាចតំណាងឲ្យទិដ្ឋភាពជាទូទៅនៃវិស័យឯកជន
  - ការផ្តល់គ្រឿងលើកទឹកចិត្តដល់វិស័យឯកជន សម្រាប់ការធ្វើវិនិយោគចម្រុះបែប និងមានរយៈពេលវែង។
- ធ្វើការសម្របសម្រួលរវាងធនធានរបស់រដ្ឋាភិបាល និងធនធានរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីអាចទទួលបានលទ្ធផលប្រសើរបំផុត ដោយបន្តការងារលើគំនិតផ្តួចផ្តើមផ្សេងៗ ដូចជា អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ជាដើម។
- អនុវត្តតាម ឬបន្តការងារក្នុងក្របខ័ណ្ឌគោលនយោបាយផ្តោតលើវិស័យជម្រុញកំណើន ដូចជា ឯកសារស្តីពីការលើកកម្ពស់ផលិតកម្មស្រូវ និងគោលនយោបាយនាំចេញស្រូវអង្ករ ជាដើម។

### ៥. លើកកម្ពស់សមត្ថភាពស្ថាប័ន ដើម្បីធ្វើពិពិធកម្មពាណិជ្ជកម្ម និងវិនិយោគ

- ផ្តល់លទ្ធភាពឲ្យស្ថាប័ន អាចអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងរៀនសូត្រពីជោគជ័យរបស់ស្ថាប័ននានានៅតំបន់សេដ្ឋកិច្ចពិសេស (SEZ) ក្នុងការបង្កើនវិនិយោគ។

១ អាទិភាពគោលនយោបាយទាំងនេះ ដកស្រង់ចេញពីបទបង្ហាញនៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១។

* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១១:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

- គ្រប់គ្រងលើការរំពឹងទុករបស់ដៃគូអភិវឌ្ឍន៍៖ ត្រូវមានជំហរច្បាស់លាស់ និងរឹងមាំ អំពីប្រវែងរយៈពេលសម្រាប់ធ្វើការកសាងសមត្ថភាពស្ថាប័ន និងត្រូវបង្កើតគោលនយោបាយទៅតាមលទ្ធភាពអាចអនុវត្តបាន។
- កាត់បន្ថយភាពមិនច្បាស់លាស់សម្រាប់វិនិយោគិនតាម៖
  - ការបង្កើតយន្តការផ្សេងៗទៀត ក្រៅពីប្រព័ន្ធតុលាការ សម្រាប់ដោះស្រាយវិវាទប្រកបដោយតម្លាភាព
  - ការបង្កើតស្ថាប័នមានចក្ខុវិស័យវែងឆ្ងាយទៅមុខ ដែលអាចផ្តល់ព័ត៌មានសំខាន់ៗ សម្រាប់វិនិយោគរយៈពេលវែង ដូចជា ថ្លៃអគ្គិសនី និងរចនាសម្ព័ន្ធទីផ្សារពលកម្ម ជាដើម។
- បន្តកាត់បន្ថយអំពើពុករលួយនៅតាមស្ថាប័នសំខាន់ៗ ដូចជា តុលាការ ជាដើម។
- បង្កើនប្រសិទ្ធភាពយន្តការសម្របសម្រួលអន្តរក្រសួង។

## ៦. បង្កើនចំណងទាក់ទងក្នុងតំបន់

- ផ្តោតការប្រឹងប្រែងលើការតម្រឹមបទបញ្ញត្តិ និងស្ថាប័ន ជាមួយនឹងប្រទេសដទៃទៀតក្នុងតំបន់ ព្រមទាំងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។
- កំណត់កំណែទម្រង់គោលនយោបាយជាក់លាក់ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយទីផ្សារសំខាន់ៗនៅ ប្រទេសឥណ្ឌា និង ចិន។
- បង្កើនកិច្ចសហប្រតិបត្តិការលើបញ្ហា "គោលនយោបាយ (សូហ្វវែរ)" ដូចជា ការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរអាកាសធាតុ ការអភិរក្ស និងការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆ្លងប្រទេស និងជំងឺឆ្លង ជាដើម។
- ផ្តោតការយកចិត្តទុកដាក់លើ ភាពជាម្ចាស់របស់អ្នកក្នុងស្រុក និងការចូលរួមក្នុងគំនិតផ្តួចផ្តើមបែប "ពីក្រោមទៅលើ" នៅក្នុងតំបន់។

## ៧. តម្រឹមការអភិវឌ្ឍកម្លាំងពលកម្ម ជាមួយនឹងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជា

- ផ្តោតការប្រឹងប្រែងលើ ការផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដើម្បីជួយឲ្យកម្លាំងពលកម្មកម្ពុជាទទួលបានជំនាញដ៏ចាំបាច់ សម្រាប់ជម្រុញវិស័យសំខាន់ៗរបស់ប្រទេសជាតិ។
- ជួយសម្រួលឲ្យមានទំនាក់ទំនងកាន់តែប្រសើរ រវាងគោលនយោបាយផ្នែកអប់រំ និងឧស្សាហកម្ម តាមរយៈ៖
  - ការសម្របសម្រួលព័ត៌មានទីផ្សារ និងការតភ្ជាប់ព័ត៌មាននេះ ទៅនឹងគោលនយោបាយវិស័យអប់រំ
  - ការបញ្ជ្រាប និងការអនុវត្តតាមកម្មវិធីបណ្តុះបណ្តាល TVET ដែលមានជោគជ័យ។
- កែប្រែទស្សនៈដែលថា TVET ជាការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតទាប ដោយដាក់អនុវត្តនូវប្រព័ន្ធទទួលស្គាល់គុណភាពជាផ្លូវការ។
- ធ្វើវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធអប់រំ និងសង្គម ដែលទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេស។

## ៨. កសាងសមត្ថភាព និងពង្រីកដែនអប់រំ

- បង្កើនលទ្ធភាពទទួលបានការអប់រំកម្រិតខ្ពស់ តាមការផ្តល់អាហារូបករណ៍ដែលផ្តោតលើក្រុមចាញ់ប្រៀបគេ (ដូចជា ជនក្រីក្រ នារី ជនជាតិភាគតិច) និងសិស្សឆ្នើម។
- សម្របសម្រួលធនធាននៃវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីបម្រើគោលដៅបានកំណត់ជាក់លាក់ ហើយញ៉ាំងឲ្យគោលនយោបាយអប់រំទទួលបានលទ្ធផលប្រសើរបំផុត។
- កែលំអគុណភាពការបង្រៀន ការសិក្សា និងការស្រាវជ្រាវនៅថ្នាក់ខ្ពស់ តាមរយៈការអនុវត្តវិធីសាស្ត្របង្រៀនបែបទំនើប ការអភិវឌ្ឍកម្មវិធីសិក្សា និងការបំពាក់ឧបករណ៍នានាដែលចាំបាច់សម្រាប់ការបង្រៀន ការសិក្សា និងការស្រាវជ្រាវនៅតាមស្ថាប័នអប់រំកម្រិតខ្ពស់ៗ។

## ៩. អភិវឌ្ឍសមត្ថភាពផ្គត់ផ្គង់សម្រាប់វិស័យពាណិជ្ជកម្ម ដោយផ្តោតលើលទ្ធភាពចូលទៅកាន់ទីផ្សារនៃសហគ្រាសធុនតូច និងមធ្យម

- ធ្វើទំនើបកម្មការដឹកជញ្ជូនឆ្លងកាត់ព្រំដែន តាមការលើកកម្ពស់ស្តង់ដារយានយន្ត និងការជួយសម្រួលឲ្យមានកំណើនការប្រកួតប្រជែងក្នុងវិស័យដឹកជញ្ជូនដែលនឹងជួយកាត់បន្ថយថ្លៃដឹកជញ្ជូន និងផលប៉ះពាល់ខាងបរិស្ថាន។
- បង្កើនភាពងាយស្រួលនៃ លទ្ធភាពចូលទៅកាន់ទីផ្សារពិភពលោក សម្រាប់សហគ្រាសធុនតូច និងមធ្យម តាមរយៈការបង្កើនចំនួនផែស្ងួត (ICD)។
- សន្សំពេលវេលា និងប្រាក់កាសនៅច្រកព្រំដែន តាមការកាត់បន្ថយសំណុំបែបបទឯកសារ ការបង្កើនម៉ោងធ្វើការរបស់គយឲ្យដល់ ២៤ម៉ោង សម្រាប់យានយន្តដឹកទំនិញឆ្លងកាត់មានលិខិតធានា ឬទៅផែស្ងួត និងការផ្តល់សេវាស្តុកទំនិញប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព សម្រាប់ទំនិញមិនទាន់ជម្រះបែបបទគយ។

## ១០. ធានាបំពេញតម្រូវការថាមពលអគ្គិសនីនៅពេលអនាគត

- ធានាបំពេញតម្រូវការថាមពលអគ្គិសនីក្នុងស្រុក សម្រាប់រយៈពេលខ្លី និងមធ្យម តាមការតម្រឹមក្របខណ្ឌនានានៃការនាំចូលអគ្គិសនីពីប្រទេសជិតខាង។
- អភិវឌ្ឍ សមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនីដោយខ្លួនឯងរបស់កម្ពុជា សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ហើយឈានទៅធ្វើការនាំចេញថាមពលអគ្គិសនី តាមរយៈការប្រើប្រាស់សក្តានុពលផលិតថាមពលវារីអគ្គិសនីនៅក្នុងស្រុក។
- ផ្តោតការប្រឹងប្រែង លើការពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនីទៅទីជនបទកម្ពុជា និងលើការបញ្ចុះថ្លៃអគ្គិសនី តាមរយៈ ទំនើបភាវូបនីយកម្ម ដើម្បីលើកទឹកចិត្តឲ្យមានវិនិយោគកាន់តែច្រើន និងមានរយៈពេលវែង។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh